# មេរៀនទី ៨: ការអស្ចារ្យដំបូងរបស់ព្រះយេស៊ូវ

## យ៉ូហាន ២:១-១១

**គោលបំណង៖** ព្រះយេស៊ូវអាចធ្វើការអស្ចារ្យ។

**ខគម្ពីរចងចាំ៖ យ៉ូហាន១:៣** *“គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវបានធ្វើជាភ្ញៀវក្នុងការចូលរួមអបអរសាទរនៅក្នុងពិធីការនៅស្រុកកាណា នេះបានបង្ហាញពីបំណងប្រាថ្នារបស់ទ្រង់ ដែលព្រះអង្គនិងចូលរួមនៅក្នុងគ្រប់ស្ថានភាពទាំងអស់នៅក្នុងជីវិតរបស់យើង ដែលរាប់បញ្ចូលទាំងពេលវេលានៃការអរសប្បាយផងដែរ។ សូមអាន**យ៉ូហាន ២:៨-១០**សារឡើងវិញ។ តើដំណើរដែលទឹកក្លាយជាស្រាទំពាងបាយជូរយ៉ាងណាដែរ វាដូចជាដំណើរការដែលព្រះបានធ្វើការនៅក្នុងជីវិតរបស់យើងដែរ តើយើងមានទំនាក់ទំនងជាមួយនិងទ្រង់នៅពេលណា? ដូចជាទំនាក់ទំនងរបស់អ្នកកំពុងលូតលាស់ជាមួយនិងព្រះដូច្នេះដែរ ទ្រង់និងបង្កើតអ្នកហើយនឹងផ្លាស់ប្រែអ្នកឲ្យកាន់តែដូចទ្រង់ថែមទៀត។ សូមអធិស្ឋានដោយអរព្រះគុណចំពោះការផ្លាស់ប្រែ ដែលធ្វើឲ្យអ្នករីករាយដោយសារទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះ-មេស្ស៊ី។

**ចំរៀង៖** ១. ព្រះយើងជាព្រះអស្ចារ្យ ២. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ ៣. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «តើអ្នកចូលចិត្តភេសជ្ជៈដែរឬទេ?»**

**សម្ភារៈដែលត្រូវការ៖** កូកា១ដប សំបកកំប៉ុងទឹកដោះគោ ទឹកសណ្តែក១ (ចាក់ទឹកដោះគោចេញ ហើយចាក់កូកាកូឡាចូល) ត្រៀមកែវក្រដាស ឬកែវប្លាស្ទិកតូចៗមួយចំនួន។




១. គ្រូពន្យល់កុមារថា ថ្ងៃនេះយើងនិងរៀនអំពីការអស្ចារ្យ សូមសួរកុមារថា តើពួកគេធ្លាប់បានឃើញការអស្ចារ្យដែរឬទេ? (អាចជាពេលដែលកូនធ្លាប់បានឃើញនរណាម្នាក់បានជាសះស្បើយពីជំងឺរបស់ពួកគេ)

២. តើមនុស្សអាចធ្វើការអស្ចារ្យបានដែរឬទេ ឬក៏មានតែព្រះមួយប៉ុណ្ណោះដែលអាចធ្វើការអស្ចារ្យបាន? សូមពន្យល់កុមារថា មានតែព្រះតែមួយអង្គប៉ុណ្ណោះ ដែលអាចធ្វើការអស្ចារ្យបានពីព្រោះទ្រង់មានអំណាច។

៣. ហេតុអ្វីបានជាអ្នកគិតថា ព្រះយេស៊ូវបានធ្វើការអស្ចារ្យ? ទ្រង់បានធ្វើការអស្ចារ្យដើម្បីបង្ហាញដល់មនុស្សទាំងអស់ថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ។

៤. សូមសួរកុមារថា នៅពេលដែលប្អូនស្រេកទឹកប្អូនប្រាកដជាត្រូវរកទឹកអ្វីមកញ៉ាំហើយមែនទេ។ គ្រូចាក់កូកាចូលទៅក្នុងកែវក្រដាសតូចៗឲ្យសិស្សញ៉ាំ។ នៅពេលដែលអស់កូកាពីដប សូមនិយាយប្រាប់កុមារថា ឥឡូវយើងអស់កូកាហើយ ប៉ុន្តែយើងនៅមានទឹកដោះគោទឹកសណ្តែក។




៥. គ្រូចាប់ផ្តើមចាក់ទឹកដោះគោចូលទៅក្នុងកែវក្រដាសរបស់ពួកគេ ពេលនោះក្មេងៗនឹងឃើញកូកាកូឡាចេញពីកំប៉ុងទឹកដោះគោទៅវិញ! ពួកគេនឹងនិយាយថា “វ៉ាវៗអស្ចារ្យណាស់! ខ្ញុំគិតថាវាជាទឹកដោះគោតែវាបែរចេញជាកូកាពីក្នុងកំប៉ុងទឹកដោះគោទៅវិញ! តើវាអាចទៅរួចបានយ៉ាងម៉េច?” ទុកឲ្យកុមារជាអ្នកឆ្លើយ។

៦. សូមពន្យល់កុមារៗថា យើងមិនអាចធ្វើការអស្ចារ្យបាននោះទេ! ប៉ុន្តែព្រះយេស៊ូវអាចធ្វើបាន។

## ៤. ការណែនាំមេរៀន

ដូចដែលយើងបានឃើញទាំងអស់គ្នាហើយថា នៅក្នុងកំប៉ុងទឹកដោះគោទឹកសណ្តែកគឺជាកូកាកូឡា។ មើលទៅដូចជាអស្ចារ្យណាស់មែនទេ! ប៉ុន្តែតាមពិតទៅវាមិនមែនទេ ព្រោះខ្ញុំ(គ្រូ)ទេតើដែលជាអ្នកចាក់កូកាកូឡាចូលក្នុងកំប៉ុងទឹកដោះគោទឹកសណ្តែកនោះ។ ប៉ុន្តែព្រះយេស៊ូវអាចធ្វើឲ្យមានការអស្ចារ្យកើតឡើងយ៉ាងពិតប្រាកដបាន។ តើការអស្ចារ្យអ្វីខ្លះដែលប្អូនសង្ឃឹមថា ព្រះយេស៊ូវនឹងធ្វើការនៅក្នុងជីវិតរបស់ប្អូន? (ទុកឱ្យកុមារឆ្លើយ)

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយព្រះយេស៊ូវបានចូលរួមពិធីមង្គលការមួយ។ នៅក្នុងពិធីមង្គលនោះកូនក្រមុំ និងកូនកំលោះបានផឹកស្រាអស់ដូចជាពួកយើងបានផឹកកូកាអស់អីចឹងដែរ។ នៅជំនាន់នោះវាជារឿងដ៏គួរឲ្យអាម៉ាស់ណាស់ ដែលនៅក្នុងពិធីមង្គលការមួយអស់ស្រាឲ្យភ្ញៀវផឹកនោះ។ វាដូចជាការដែលអ្នកបានអញ្ជើញភ្ញៀវឲ្យទៅផ្ទះរបស់អ្នកដើម្បីញ៉ាំអាហារពេលល្ងាច ហើយនៅពេលភ្ញៀវមិនទាន់ទាំងបានញ៉ាំគ្រប់គ្នាស្រាប់តែអស់ម្ហូបបាត់។ នៅពេលនោះម្តាយរបស់ព្រះយេស៊ូវបានសុំឲ្យទ្រង់ធ្វើអ្វីម្យ៉ាងចំពោះបញ្ហានេះ។ ព្រះយេស៊ូវមានបន្ទូលទៅអ្នកបម្រើនៅក្នុង **យ៉ូហាន ២:៧** ថា “ចូរចាក់ទឹកឲ្យពេញពាងទាំងនេះទៅ គេក៏ចាក់ទឹកពេញដល់មាត់ពាង។”

រួចទ្រង់មានបន្ទូលប្រាប់គេថា **យ៉ូហាន ២:៨** “ឥឡូវនេះចូរដងយកទៅជូនដល់លោកជាមង្គលការចុះ” ពួកអ្នកបម្រើក៏ធ្វើតាមអ្វីដែលព្រះយេស៊ូវបានបង្គាប់។ នោះអ្នកដែលមកចូលរួមក៏បាននិយាយថា **យ៉ូហាន២:១០** “មនុស្សទាំងឡាយគេតែងតែលើកស្រាទំពាំងបាយជូរល្អមកជាមុន លុះកាលបានផឹកជាច្រើនហើយនោះ ទើបលើកស្រាទំពាំងបាយជូរដែលមិនសូវល្អមកជាក្រោយ តែនេះអ្នកបានទុកស្រាទំពាំងបាយជូរយ៉ាងល្អដរាបដល់ឥឡូវនេះវិញ” ។ តើមានអ្វីកើតឡើង? ព្រះយេស៊ូវបានធ្វើឲ្យទឹកក្លាយជាស្រាទំពាងបាយជូរ!

សាកស្រមៃមើលថា នៅពេលនោះតើអ្នកបម្រើមានការភ្ញាក់ផ្អើលប៉ុនណាទៅ? ដោយពួកគេគ្រាន់តែចាក់ទឹកទៅឲ្យភ្ញៀវប៉ុណ្ណោះតែពួកគេបែរជានាំគ្នានិយាយថា វាគឺជាស្រាទំពាងបាយជូរទៅវិញ! ព្រះយេស៊ូវបានធ្វើការអស្ចារ្យនេះដើម្បីជួយកូនក្រមុំ និងកូនកំលោះ ហើយទ្រង់ក៏ចង់បង្ហាញទៅមនុស្សគ្រប់គ្នាថា ទ្រង់ជាព្រះរាជបុត្រារបស់ព្រះដែលមានអំណាចផងដែរ។

នេះជាការអស្ចារ្យដំបូងបំផុតដែលព្រះយេស៊ូវបានធ្វើ ហើយវាធ្វើឲ្យអ្នកជឿលើទ្រង់មានការភ្ញាក់ផ្អើល។ បើទោះជាពេលសព្វថ្ងៃនេះក៏ដោយ នៅពេលណាដែលយើងឮអំពីរឿងនេះ យើងក៏នៅតែគិតថាជារឿងដែលអស្ចារ្យដែរ។ ព្រះអង្គជាព្រះតែមួយគត់ ដែលអាចធ្វើឲ្យមានការអស្ចារ្យកើតឡើងយ៉ាងពិតប្រាកដបាន។ ការអស្ចារ្យនេះបង្ហាញថា ព្រះយេស៊ូវជាព្រះ!

**៦. សំនួរពិភាក្សា**

១. តើមានអ្វីកើតឡើងនៅក្នុងកម្មវិធីមង្គលការ? *ពួកគេអស់ស្រាទំពាងបាយជូរ*

២. តើនរណាជាអ្នកស្នើសុំឲ្យព្រះយេស៊ូវធ្វើអ្វីមួយសំរាប់បញ្ហានេះ? *ម្ដាយរបស់ព្រះយេស៊ូវ*

៣. តើព្រះយេស៊ូវបានបានប្រើអ្នកបំរើឲ្យយកអ្វីមកចាក់ទៅក្នុងពាង? *ទឹក*

៤. តើមានរឿងអ្វីកើតឡើងនៅពេលដែលអ្នកមកចូលរួមកម្មវិធីបានផឹកទឹកនោះ?
*គាត់បាននិយាយថាកូនក្រមុំ និងកូនកំលោះបានរក្សាទុកស្រាទំពាងបាយជូរដ៏ល្អបំផុតមកដល់ពេលនេះ*

៥. តើមាននរណាអាចគិតអំពីការអស្ចារ្យខ្លះៗដែលយើងត្រូវការឥឡូវនេះបានទេ? *ទុកឲ្យកុមារជាអ្នកឆ្លើយ*

៦. តើប្អូនៗជឿថាព្រះអាចធ្វើការអស្ចារ្យនៅក្នុងជីវិតរបស់ប្អូន ដែលជាមនុស្សធម្មតាទៅជាមនុស្សពិសេសនៅក្នុងភូមិ សហគមន៍ឬប្រទេសទាំងមូលដែរឬទេ? *ទុកឲ្យកុមារជាអ្នកឆ្លើយ*

**៧. ខគម្ពីរចងចាំ** **យ៉ូហាន ១:៣**

**៨. ហាត្ថកម្ម** **« កាសែតវេទមន្ត »**

**សម្ភារៈដែលត្រូវការ៖** សូមបោះពុម្ពក្រដាសកាសែតសម្រាប់កុមារ (មើលនៅខាងក្រោម)

១. ឲ្យកុមារនិយាយប្រាប់មិត្តភក្ដិរបស់ពួកគេពីដំណើររឿងដ៏អស្ចារ្យដែល ព្រះយេស៊ូវបានធ្វើការអស្ចារ្យរបស់ទ្រង់ជាលើកដំបូង។

២. ពួកគេត្រូវគូសរូបភាពនៅក្នុងប្រអប់ (ដូចជារូបភាពដែលមាននៅក្នុងក្រដាសកាសែតផ្សេងៗ) ហើយឲ្យគេសរសេរជាសាច់រឿងខ្លីនៅលើបន្ទាត់ដែលគូសស្រាប់ដោយពន្យល់ថា តើមានអ្វីដែលបានកើតឡើង ហើយហេតុអ្វីបានជាការនោះមានសារៈសំខាន់។

៣. បន្ទាប់មកកុមារអាចសរសេរពីក្ដីស្រមៃនៅថ្ងៃអនាគតរបស់ពួកគេ ដោយទុកចិត្តថា ព្រះយេស៊ូវនឹងធ្វើការអស្ចារ្យនៅក្នុងជីវិតរបស់ពួកគេ។

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ពត៌មានប្រចាំថ្ងៃនៅកម្ពុជា

## ការអស្ចារ្យដំបូងរបស់ព្រះយេស៊ូវ

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

ក្ដីស្រមៃនៅថ្ងៃអនាគត______________________________________________________

______________________________________________________________________